ព្រឹទ្ធសភា

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# របាយការណ៍
# ស្តីពី
# លទ្ធផលការងាររបស់ព្រឹទ្ធសភា
# ប្រចាំខែសីហា ឆ្នាំ២០១៤

នៅក្នុងខែសីហា ឆ្នាំ២០១៤នេះ ព្រឹទ្ធសភាបានបំពេញភារកិច្ចរបស់ខ្លួនដូចតទៅ៖

## ១.សកម្មភាពថ្នាក់ដឹកនាំព្រឹទ្ធសភា

### ១.១ សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម ប្រធានព្រឹទ្ធសភា បាន៖

-បានទទួលភារកិច្ចជាប្រមុខរដ្ឋស្តីទីចំនួន០១លើក

-ចុះហត្ថលេខាលើកំណត់ហេតុសង្ខេប និងកំណត់ហេតុពិស្តារ នៃការប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ នីតិកាលទី៣ ចំនួន០៤ច្បាប់ និងប្រជុំព្រឹទ្ធសភាចំនួន០៦ច្បាប់

-ចុះហត្ថលេខាលើលិខិតផ្សេងៗចំនួន២៧លិខិត ។

### ១.២ ឯកឧត្តម សាយ ឈុំ អនុប្រធានទី១ព្រឹទ្ធសភា បាន៖

-ទទួលភារកិច្ចជាប្រធានស្តីទីព្រឹទ្ធសភាចំនួន០១លើក

-អញ្ជើញដឹកនាំកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ចំនួន០២លើក និងកិច្ចប្រជុំពេញអង្គព្រឹទ្ធសភាចំនួន០១លើក

-បានទទួលឯកឧត្តម Azuma KOSHIISHI អនុប្រធានព្រឹទ្ធសភាជប៉ុន ចូលជួបសវនការ និងសម្តែងការគួរសម

-បានអញ្ជើញចុះពិនិត្យស្ថានភាពទឹកលិចផ្ទះប្រជាពលរដ្ឋ ក្នុងភូមិបឹងឈូក សង្កាត់និរោធន៍ ខណ្ឌច្បារពៅ និងដោះស្រាយផ្តល់ម៉ាស៊ីនបូមទឹក ( ទុយោទំហំ៣តឹក) ចំនួន០៣គ្រឿង សំរាប់បូមរំដោះទឹកចេញពីប្រឡាយព្រែកបារាំង ដើម្បីទប់ស្កាត់កុំឲ្យទឹកទន្លេហូរចូលលិចភូមិ និងផ្ទះប្រជាជនក្នុងភូមិសាស្ត្រ សង្កាត់និរោធន៍ ខណ្ឌច្បារអំពៅទី១ និងសង្កាត់ព្រែកប្រា នៃខណ្ឌច្បារអំពៅ

-បានអញ្ជើញចុះពិនិត្យ និងជួបគណៈនាយកវិទ្យាល័យច្បារអំពៅ និងបានសម្រេចឧបត្ថម្ភ



វិមានរដ្ឋចំការមន មហាវិថីព្រះនរោត្តម រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ: (855 23) 211 441, 211 442, 211 443 ទូរសារ: (855 23) 211 446, E-mail: oum_sarith@camnet.com.kh

ការសាងសង់ទីលានទាត់បាល់មួយកន្លែងក្នុងវិទ្យាល័យ សំរាប់សិស្ស និងយុវជនក្នុងមូលដ្ឋាន ក្នុងឱកាសនោះដែរឯកឧត្តមក៏បានទទួលនូវសំណើសុំជួយជួសជុលអាគារសិក្សា០៣ខ្នង ដែលមានភាពចាស់ទ្រុឌទ្រោមខ្លាំង និងបានណែនាំឲ្យធ្វើការសិក្សាគំរោងជួសជុលអាគារទាំងនោះដើម្បីរកសប្បុរសជនជួយជួសជុលជូន

-ពិនិត្យ ផ្តល់យោបល់ និងចុះហត្ថលេខាលើឯកសារផ្សេងៗចំនួន១៣៨ច្បាប់ ។

**១.៣ ឯកឧត្តម ទេព ងន អនុប្រធានទី២ ព្រឹទ្ធសភាបានៈ**

-អញ្ជើញចូលរួមកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ចំនួន០២លើក

-អញ្ជើញចូលរួមយាងព្រះរាជដំណើរ **ព្រះករុណា ព្រះបាទ នរោត្តម សីហមុនី** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា និងសម្តេចព្រះវររាជមាតាជាតិខ្មែរ ស្តេចយាងទៅពិនិត្យ ព្រះរាជសុខភាព និងបំពេញព្រះរាជទស្សនកិច្ចនៅខេត្តមួយ នៃសាធារណរដ្ឋប្រជាមានិតចិន

-អញ្ជើញចូលរួមប្រជុំរៀបចំក្បាលម៉ាស៊ីនដឹកនាំរបស់ព្រឹទ្ធសភាចំនួន០២លើក

-បានទទួលឯកឧត្តម Naoto Sakaguchi សមាជិករដ្ឋសភាជប៉ុន ចូលជួបសម្តែងការគួរសម

-បានទទួលឯកឧត្តម Kumamaru Yuji ឯកអគ្គរាជទូតវិសាមញ្ញ និងពេញដោយសមត្ថភាពនៃព្រះរាជាណាចក្រជប៉ុន ចូលជួបពិភាក្សាការងារ

-អញ្ជើញថ្លែងសន្ទរកថាបើកសិក្ខាសាលាស្តីពី "ការប្រាស្រ័យឆ្លើយឆ្លងរវាងសភា និងប្រព័ន្ធផ្សព្វផ្សាយប្រកបដោយប្រសិទ្ធភាព"

-បាននាំយកទៀនព្រះវស្សាទៅប្រគេនដល់ព្រះសង្ឃដែលគង់ក្នុងវត្តចំនួន០៥ ស្ថិតនៅស្រុកទ្រាំង ខេត្តតាកែវ

-អញ្ជើញចូលរួមជាកិត្តិយសក្នុងពិធីសំណេះសំណាល និងពិសាអាហារសាមគ្គីនៅស្ថានឯកអគ្គរដ្ឋទូតសាធារណរដ្ឋប្រជាមានិតចិន

-អញ្ជើញអធិបតីភាពក្នុងពិធីលៀងសាយភោជន៍ជូនឯកឧត្តម Azuma Koshiishi អនុប្រធានព្រឹទ្ធសភាជប៉ុន

-ពិនិត្យ ផ្តល់យោបល់ និងចុះហត្ថលេខាលើឯកសារផ្សេងៗចំនួន៩៣ច្បាប់ ។

**២.សម័យប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ចំនួន ០២លើក ដើម្បី ៖**

១-ពិនិត្យ និងសម្រេចបង្កើតគណៈកម្មការពិសេស ដើម្បីពិនិត្យសិក្សាលើសំណើវិសោធនកម្មប្រការ១៥ នៃបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា

២-ពិនិត្យ និងសម្រេចលើសំណើរបស់គណៈកម្មការពិសេស សុំដាក់សេចក្តីស្នើវិសោធន

កម្មប្រការ១៩ នៃបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា ទៅក្នុងរបៀបវារៈសម័យប្រជុំលើកទី៩ព្រឹទ្ធសភា នីតិកាលទី៣។

៣-ពិនិត្យ និងសម្រេចលើបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោតជ្រើសតាំងសមាជិកក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយ។

៤-កំណត់របៀបវារៈ និងកាលបរិច្ឆេទបន្តសម័យប្រជុំលើកទី៩ ព្រឹទ្ធសភា នីតិកាលទី៣។

**៣.សម័យប្រជុំពេញអង្គចំនួន ០១លើក ដើម្បី ៖**

១-ពិនិត្យ និងអនុម័តសេចក្តីស្នើវិសោធនកម្មប្រការ១៩ នៃបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា

២-បោះឆ្នោតជ្រើសតាំងសមជិកក្រុមប្រឹក្សាប្រឆាំងអំពើពុករលួយមួយរូប ។

**៤.គណៈកម្មការជំនាញនានារបស់ព្រឹទ្ធសភា**

ក្នុងខែសីហានេះ សមាជិក សមាជិកាព្រឹទ្ធសភា បានបំពេញការងារយ៉ាងសកម្មតាមតួនាទី ភារកិច្ច និងសមត្ថកិច្ចរបស់ខ្លួនប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ដូចខាងក្រោម៖

**៤.១ មុខងារនីតិកម្ម**

-ប្រជុំគណៈកម្មការពិសេសព្រឹទ្ធសភា ដើម្បីពិនិត្យលើសំណើវិសោធនកម្មប្រការ១៩ នៃបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា

-ប្រជុំពិនិត្យ និងផ្ទៀងឯកសារស្តីពី " សេចក្តីកំណត់ និងនីតិវិធីអនុវត្តចំពោះប្រការទាំងឡាយនៃបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា "

-ប្រជុំពិនិត្យ និងពិភាក្សាស្តីពី "គម្រោងថវិកាឆ្នាំ២០១៩ របស់ព្រឹទ្ធសភា "ជាមួយថ្នាក់ដឹកនាំក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**៤.២ មុខងារតំណាង**

-បញ្ជូនលិខិតទៅស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ នឹងការដោះស្រាយពាក្យបណ្តឹងបានចំនួន០៥ករណី តម្កល់ទុកមិនចាត់ការចំនួន០១ករណី ទទួលលិខិតឆ្លើយតបពីការដោះស្រាយពាក្យបណ្តឹងចំនួន០២ករណី និងផ្ញើលិខិតជំរុញការដោះស្រាយពាក្យបណ្តឹងទៅក្រសួងស្ថាប័នពាក់ព័ន្ធចំនួន០២ករណី

-ប្រជុំពិភាក្សាការងារ និងត្រៀមឯកសារដើម្បីចូលរួមក្នុងសន្និសីទសភាប៉ាស៊ីហ្វិកលើកទី១៧ស្តីពី បរិស្ថាននិងការអភិវឌ្ឍ(APPCED)

-បទបង្ហាញស្តីពី "តួនាទី ភារកិច្ចរបស់គណៈកម្មការទី១ និងសមិទ្ធផលក្នុងវិស័យលើកកម្ពស់សិទ្ធិមនុស្ស " ជូនដល់និស្សិត និងបេក្ខជនថ្នាក់បណ្ឌិត ដែលមកពីសាកលវិទ្យាល័យនៃប្រទេសអាល្លឺម៉ង់ សាកលវិទ្យាល័យប្រទេសអាមេរិក និងសាកលវិទ្យាល័យក្នុងព្រះរាជាណាចក្រកម្ពុជា

-ជួបពិភាក្សាការងារជាមួយលោក Daniel Heilmann ទីប្រឹក្សាច្បាប់ជាន់ខ្ពស់អាល្លឺម៉ង់ប្រចាំព្រឹទ្ធសភា អំពីខ្លឹមសារនៃការរៀបចំសិក្ខាសាលាអបអរសាទរទិវាសិទ្ធិមនុស្សអន្តរជាតិ ១០ ធ្នូ ខួបលើកទី៦៦ ឆ្នាំ២០១៤

-ជួបពិភាក្សាការងារជាមួយលោក **គឹមយាត ដារ៉ារិទ្ធ** នាយកប្រតិបត្តិនៃវិទ្យាស្ថានសភាកម្ពុជា អំពីការបន្តកិច្ចសហប្រតិបត្តិការរវាងវិទ្យាស្ថានសភាកម្ពុជា និងព្រឹទ្ធសភា

-ជួបសំណេះសំណាល និងពិភាក្សាការងារជាមួយលោក Yuji Kumamru ឯកអគ្គរាជទូតជប៉ុនប្រចាំកម្ពុជាស្តីពី វិស័យសិទ្ធិមនុស្សទាក់ទងនឹងការសិក្សានៅប្រទេសជប៉ុន

-សំណេះសំណាលជាមួយក្រុមប្រឹក្សាឃុំ និងប្រធានភូមិតាពូង អំពីសភាពការណ៍បន្តបង្កើនផលកសិកម្ម និងបញ្ហាផ្សេងៗ

-អនុញ្ញាតឲ្យកញ្ញា Zhang Yan Ping អ្នកព័ត៌មាននៃវិទ្យុមិត្តភាពកម្ពុជា-ចិន ចូលជួបសំណេះសំណាល និងពិភាក្សាការងារ

-បទបង្ហាញស្តីពី "រចនាសម្ព័ន្ធតួនាទី ភារកិច្ចរបស់ព្រឹទ្ធសភា" ដល់ក្រុមប្រឹក្សាឃុំ សង្កាត់ និងសហគមន៍ខេត្តកំពង់ឆ្នាំង

-ចូលរួមសិក្ខាសាលាស្តីពី "ការចុះបញ្ជាំងភាពជាដៃគូរក្នុងការបើកចំហព័ត៌មានសាធារណៈ និងការដោះស្រាយបញ្ហាក្នុងសហគមន៍ដើម្បីដំណើរការឆ្ពោះទៅរកអភិបាលកិច្ចល្អ" នៅខេត្តកំពង់ឆ្នាំង

-ចូលរួមសិក្ខាសាលាស្តីពី " ការលើកកម្ពស់ការប្រាស្រ័យឆ្លើយឆ្លងរវាងសភា និងប្រព័ន្ធផ្សព្វផ្សាយប្រកបដោយប្រសិទ្ធភាព"

-ចូលរួមសិក្ខាសាលាស្តីពី "ការថែទាំ ការប្រមូលផល និងការនាំចេញស្វាយនៅកម្ពុជា"

-ចូលរួមសន្និសីទជាតិស្តីពី "សហគមន៍អាស៊ាន២០១៥ និងដំណាក់កាលនៃការត្រៀមខ្លួន និងការប្រឈមរបស់កម្ពុជា"

សមាជិក សមាជិកាព្រឹទ្ធសភា បានចុះទៅតាមបណ្តាខេត្ត-រាជធានីទូទាំងប្រទេសចំនួន ៦៨លើក ដើម្បីចុះជួប និងជួយប្រជាពលរដ្ឋរងគ្រោះដោយទឹកជំនន់ និងគ្រោះរាំងស្ងួត ជួបពិភាក្សាការងារ សាកសួរសុខទុក្ខសមាជិកក្រុមប្រឹក្សាឃុំ-សង្កាត់ ប្រជាពលរដ្ឋ ពិនិត្យការដ្ឋានសាងសង់ សម្ពោធសមិទ្ធផលនានា តាមដានការអនុវត្តគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការនៅថ្នាក់ក្រោមជាតិ ការអនុវត្តគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព ស្វែងយល់អំពីស្ថានភាពសិទ្ធិមនុស្ស ការអនុវត្តច្បាប់ កែលម្អសេវាសាធារណៈ ពង្រឹងអភិបាលកិច្ចល្អនៅមូលដ្ឋាន និងគោលនយោបាយផ្សេងៗលើគ្រប់វិស័យ ព្រមទាំងបានចូលរួមក្នុងពិធី

ផ្ទៃការ និងពិធីផ្សេងៗសរុបចំនួន៣៩លើក។

**៤.៣ មុខងារព័ត៌មាន**

-ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៧ បានបំពេញបេសកកម្មតាមដានត្រួតពិនិត្យ និងប្រមូលព័ត៌មានស្តីអំពី "ការចុះបញ្ជាំងភាពជាដៃគូរ ក្នុងការបើកចំហព័ត៌មានសាធារណៈ និងការដោះស្រាយបញ្ហាក្នុងសហគមន៍ដើម្បីដំណើរឆ្ពោះទៅរកអភិបាលកិច្ចល្អ " នៅទីរួមខេត្តកំពង់ឆ្នាំង។

**៤.៤ មុខងារត្រួតពិនិត្យ**

-គណៈកម្មការទី៨ បានជួបសវនាការជាមួយមន្ត្រីជំនាញ នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដើម្បីពិភាក្សារៀបចំសិក្ខាសាលាស្តីពី" ប្រព័ន្ធប្រឡងប្រណាំងការបណ្តុះបណ្តាលវិជ្ជាជីវៈ និងការលើកកម្ពស់សមត្ថភាព" និង"ការធ្វើទស្សនកិច្ចនៅគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈមួយចំនួន" ក្រោមការគ្រប់គ្រងផ្ទាល់របស់ក្រសួង។

**៥.កិច្ចសហប្រតិបត្តិការអន្តរជាតិ**

-សមាជិក-សមាជិកាគណៈកម្មការទី៩ ដឹកនាំដោយលោកជំទាវ **ទី បូរ៉ាស៊ី** បានទៅទស្សនកិច្ចដកបទពិសោធន៍ការងារ នៅសាធារណរដ្ឋប្រជាមានិតចិន ។

-ឯកឧត្តម **ឈិត គឹមយាត** បានអញ្ជើញចូលរួមប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ទទួលបន្ទុកកិច្ចការសង្គម និងវប្បធម៌ នៅទីក្រុងតេរ៉ង់ សាធារណរដ្ឋអ៊ីស្លាមអ៊ីរ៉ង់ ។

-សម្តេចរាជបុត្រីព្រះរៀម **នរោត្តម បុប្ផាទេវី** បានយាងទៅធ្វើទស្សនកិច្ច និងចូលរួមក្នុងព្រះរាជពិធីរំលឹកខួបលើកទី៣ នៃគុណបការៈថ្វាយចំពោះព្រះករុណា ព្រះមហាវីរក្សត្រ ព្រះវររាជបិតា ព្រះបាទព្រះនរោត្តមសីហនុ ព្រះបរមរតនកោដ្ឋ ដែលប្រារព្ធធ្វើនៅ (Royal Grand Hall Buddhism) ប្រទេសជប៉ុន ។ Th

រាជធានីភ្នំពេញ, ថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០១៤

**ជ.ប្រធានព្រឹទ្ធសភា**

**អនុប្រធានទី២**

**ទេព ងន**

ចម្លងជូនៈ
- ក្រសួងព្រះបរមរាជវាំង
- ក្រុមប្រឹក្សាធម្មនុញ្ញ
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- ក្រសួងយុត្តិធម៌
- ក្រសួងព័ត៌មាន
- (ទូលថ្វាយ និងជូនជ្រាបជាព័ត៌មាន)
- កាលប្បវត្តិ-ឯកសារ